ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ...2.4.0......សសរ.កសក

# សេចក្តីសំរេច

## ស្តីពីការតែងតាំងគណៈកម្មការប្រឹក្សាថ្នាក់ជាតិសំរាប់រៀបចំឯកសារ និង ស្រាវជ្រាវពូជសត្វនៅកម្ពុជា

***********

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ខែ វិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តាមសំណើលិខិតលេខ ៣៤៦ ផប ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០២ របស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ស្តីពីសំណើសុំបង្កើតគណៈកម្មការប្រឹក្សាថ្នាក់ជាតិដែលហៅកាត់ថា **NCC**

## សំរេច

**ប្រការ១:** តែងតាំងគណៈកម្មការប្រឹក្សាថ្នាក់ជាតិ សំរាប់រៀបចំឯកសារ និង ស្រាវជ្រាវពូជសត្វនៅកម្ពុជាដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោក | **សួន សុធឿន** | អនុប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល | ជាប្រធាន |
| ២- លោក | **លីម ចាន់ធី** | អនុប្រធានការិយាល័យផលិតកម្ម | ជាអ្នកសំរបសំរួល |

| | | |
|---|---|---|
| ៣-លោក **ស៊ិន ឆៅ** | មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល | ជាលេខាធិការ |
| ៤-កញ្ញា **ហោ ម៉ាលីន** | មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល | ជាលេខាធិការ |
| ៥-លោក **អ៊ុំ សុគន** | មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល | ជាលេខាធិការ |
| ៦-លោក **សរិន កុសល** | អនុប្រធានការិយាល័យផែនការគណនេយ្យ | ជាសមាជិក |
| ៧-លោក **ជន សុទីវ៉ា** | មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល | ជាសមាជិក |
| ៨-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកណ្ដាល | | ជាសមាជិក |
| ៩-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តក្រចេះ | | ជាសមាជិក |
| ១០-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តបាត់ដំបង | | ជាសមាជិក |
| ១១-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តស្ទឹងត្រែង | | ជាសមាជិក |
| ១២-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តស្វាយរៀង | | ជាសមាជិក |
| ១៣-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តពោធិសាត់ | | ជាសមាជិក |
| ១៤-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តសៀមរាប | | ជាសមាជិក |
| ១៥-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពត | | ជាសមាជិក |
| ១៦-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពង់ស្ពឺ | | ជាសមាជិក |
| ១៧-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពង់ឆ្នាំង | | ជាសមាជិក |
| ១៨-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពង់ធំ | | ជាសមាជិក |

**ប្រការ២:** ក្រុមការងារនេះមានភារកិច្ចរៀបចំឯកសារ និង ស្រាវជ្រាវពូជសត្វនៅកម្ពុជា តាមឯកសារគោលនយោបាយផលិតកម្មសត្វ ដើម្បីផ្ញើជូនអង្គការ FAO ប្រចាំតំបន់នៅ ខែ សីហា ឆ្នាំ ២០០២ខាងមុខនេះ ។

**ប្រការ៣:** ប្រធានក្រុមការងារមានសិទ្ធិជ្រើសរើសសមាសភាពបន្ថែម ដើម្បីធ្វើជាជំនួយការ និង អញ្ជើញសមាជិកដើម្បីមកប្រជុំតាមការចាំបាច់ ។

**ប្រការ៤:** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាន នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង សាមីជនត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធិ ភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២

ច័ន្ទ-សារុន

**កន្លែងទទួល:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ